+855 (0)17774864
www.sasabassac.com

#18 2nd Floor, Sothearos Boulevard
PO Box 2181 Phnom Penh 3, Cambodia

សាសាបាសាក់ SA SA BASSAC

# គ្មានចំណងជើង

## ដោយ ខ្វៃ សំណាង

គាត់បានឃើញមនុស្សកំពុងរុះរើផ្ទះមួយនៅលើទឹក។ គាត់បានសួរអ្នកទាំងនោះថាតើទឹកនេះជ្រៅឬទេ។ ពួកគេបានឆ្លើយថា«ជ្រៅ»។ គាត់ក៏បានចាប់ផ្ដើមចុះហែលក្នុងទឹក។ មនុស្សម្នាក់បានរំលឹកគាត់ថាទឹកនេះមិនស្អាតទេ។គាត់បានហែលទៅរកបង្គោលឈើមួយ។គាត់បានចងផ្អោបខ្លួនគាត់ទៅនឹងបង្គោលនោះ។ ខ្លួនរបស់គាត់បានជាប់ជាមួយនឹងចំណងខ្សែ។ គាត់បានចាក់ខ្សាច់មួយធុងទៅលើក្បាលគាត់។

គាត់បានឃើញគ្រួសារមួយកំពុងលីបំណែកផ្សេងៗនៃផ្ទះរបស់គេ។ គាត់បានហែលទៅ កាន់បង្គោលឈើមួយ។ គាត់បានចងផ្អោបខ្លួនគាត់ទៅនឹងបង្គោលនោះ។ ខ្លួនរបស់គាត់បានជាប់ជាមួយនឹងចំណងខ្សែ។ គាត់បានចាក់ខ្សាច់មួយធុងទៅលើក្បាលគាត់។

គាត់បានទៅតំបន់មានទឹកមួយដែលមានផ្ទះជាច្រើន។ គាត់បានឃើញឈ្មោះនិងអាសយដ្ឋាននៅលើខ្លោងទ្វារផ្ទះ។ នៅពេលដែលគាត់ដើរចុះក្នុងទឹក គាត់សង្កេតឃើញមានប្រជាជនមើលមកកាន់គាត់។ មនុស្សម្នាក់បានសួរគាត់ថា តើគាត់ជាតួកុនកំពុងថតរឿងមែនទេ។ គាត់បានឆ្លើយថា «ខ្ញុំកំពុងបង្កើតស្នាដៃសិល្បៈ»។ នៅក្នុងទឹកនោះ គាត់បានរកឃើញសសរឈើមួយសំរាប់អង្គុយលើ។ គាត់បានចាក់ខ្សាច់មួយធុងទៅលើក្បាលគាត់។

គាត់បានឃើញសំរាមជាច្រើនអណ្តែតនៅលើទឹក។ គាត់បានចាប់ផ្តើមហែលនៅក្នុងទឹកដែលពោរពេញទៅដោយសំរាមនោះ ហើយស្វែងរកកន្លែងសុវត្ថិភាពមួយដែលគាត់អាចឈរបាន។ គាត់បានរកឃើញបន្ទះក្តារមួយនៅក្នុងទឹកដែលគាត់អាចឈរលើបាន។ គាត់បានចាក់ខ្សាច់មួយធុងទៅលើក្បាលគាត់។

គាត់បានឃើញផ្ទះជាច្រើនលិចទឹក។ គាត់បានជួលក្មេងប្រុសម្នាក់អោយជួយអុំទូកចម្លងគាត់ទៅកាន់ផ្ទះលិចទឹកមួយ។ គាត់បានចុះក្នុងទឹក ហើយស្វែងរកកន្លែងដែលអាចទ្រទម្ងន់របស់គាត់បាន។ គាត់បានរកឃើញធ្នើរមួយដែលជាប់នឹងបង្គោលឈើ។ គាត់បានឈរលើធ្នើរនោះ។ គាត់បានចាក់ខ្សាច់មួយធុងទៅលើក្បាលគាត់។

គាត់បានឃើញកន្លែងតូចមួយមានទឹក ដែលពីមុនធ្លាប់ជាតំបន់ដែលមានទឹកយ៉ាងធំ។ នៅឆ្ងាយបន្តិច គាត់បានឃើញមានខ្សាច់ និងគ្រឿងម៉ាស៊ីនមួយចំនួន។ គាត់បានដើរកាត់ព្រៃស្មៅ ហើយខ្លួនគាត់បានមុតបន្លា។ គាត់បានចាក់ខ្សាច់មួយធុងទៅលើក្បាលគាត់។

គាត់បានឃើញរុក្ខជាតិដុះប្រជ្រៀតគ្នានៅលើទឹក។ នៅឆ្ងាយបន្តិច គាត់បានឃើញមានអាគារមួយចំនួន។ ប្រជាជនបានប្រាប់គាត់ថា «ទឹកនេះជ្រៅណាស់»។ ពួកគេបានប្រាប់គាត់ទៀតថា «ផ្ទះល្វែងទាំងនោះភាគច្រើនគ្មានមនុស្សនៅទេ»។ គាត់បានរកឃើញឈើពីរកំណាត់ ហើយក៏ដាក់វានៅពីលើរុក្ខជាតិនោះ។ គាត់បានឈរពីលើកំណាត់ឈើនោះ។ គាត់បានចាក់ខ្សាច់មួយធុងទៅលើក្បាលគាត់។

គាត់បានឃើញរុក្ខជាតិដុះជាជួរនៅលើទឹក។ នៅឆ្ងាយបន្តិច គាត់បានឃើញមានខ្សាច់។ គាត់បានដើរចុះទៅក្នុងទឹករាក់នោះ។ គាត់បានចាក់ខ្សាច់មួយធុងទៅលើក្បាលគាត់។

គាត់បានឃើញខ្សាច់ ដែលពីមុនជាកន្លែងមានទឹក។ គាត់បានដើរនៅលើខ្សាច់ រួចឆ្លងកាត់ស្មៅ។ គាត់បានចាក់ខ្សាច់មួយធុងទៅលើក្បាលគាត់។

**អំពីសិល្បករ៖**

ខ្វៃ សំណាង ឆ្លុះបញ្ចាំងអំពីទិដ្ឋភាពផ្សេងៗនៅក្នុងសង្គមកម្ពុជា ដើម្បីចោទជាសំណួរស្តីពីផលប៉ះពាល់និងទំនាក់ទំនងរបស់បញ្ហាទាំងនោះនៅក្នុងពេលបច្ចុប្បន្ន ប្រកបដោយភាពល្អិតល្អន់ និងកំប្លុកកំប្លែង។ សំណាង (កើតនៅខេត្តស្វាយរៀង ក្នុងឆ្នាំ១៩៨២) បានទទួលបរិញ្ញាបត្រផ្នែកវិចិត្រសិល្បៈ ជំនាញវិចិត្រកម្ម ពីសកលវិទ្យាល័យភូមិន្ទវិចិត្រសិល្បៈ នៅទីក្រុងភ្នំពេញ ឆ្នាំ ២០០៦។ ស្នាដៃរបស់គាត់ត្រូវបានដាក់តាំងយ៉ាងទូលំទូលាយនៅក្នុងប្រទេសកម្ពុជា ហើយពិព័រណ៍អន្តរជាតិរបស់គាត់រួមមាន *រាត្រីប្រចាំឆ្នាំនៃមហោស្រពរូបថត Arles* ប្រទេសបារាំង (២០០៨,២០១១) *តាំងពីមុនមកទល់បច្ចុប្បន្ន* នៅវិចិត្រសាល 10 Chancery Lane ទីក្រុងហុងកុង (២០០៩) *តូក្យូ ២០១០* នៅ Tokyo Wonder Site Hongo (២០១១)។ សំណាងគឺជាសិល្បករបានស្នាក់នៅ Tokyo Wonder Site Aoyama (២០១០)។

# Untitled

## Khvay Samnang

He saw people dismantling a house built above water. He asked them if the water was deep. They replied, “Yes.” He began swimming in the water. One person warned him that the water was not clean. He swam to a wooden post. He connected a length of wire to the post and around his body. His body hung from the wire. He poured a bucket of sand over his head.

He watched a family carrying pieces of their house. He swam to a wooden post. He connected a length of wire to the post and around his body. His body hung from the wire. He poured a bucket of sand over his head.

He went to an area of water that had many houses. He saw names and addresses written above the doorways. He entered the water and noticed the residents watching him. One person asked him if he was an actor making a film. He replied, “I am making art.” In the water, he found a piece of wood to sit on. He poured a bucket of sand over his head.

He saw a lot of garbage floating in the water. He began swimming in the water and garbage in search of a secure place to stand. He found a piece of wood below the water, where he stood. He poured a bucket of sand over his head.

He noticed water flooding many houses. He hired a young boy to paddle a boat towards one of the flooded houses. He entered the water in search of a secure place to support his weight. He found a shelf attached to a wooden post. He stood on the shelf. He poured a bucket of sand over his head.

He noticed a small area of water where there was once a big area of water. In the distance, he saw sand and machines. He walked through the grasses, whose blades cut his body. He poured a bucket of sand over his head.

He saw dense plant life on the water. In the distance he saw a cluster of buildings. People told him, “The water is very deep.” People also told him, “The apartments are mostly empty.” He found two pieces of wood and placed them on top of the plants. He stood on the wood. He poured a bucket of sand over his head.

He saw a pattern of plant life on the water. In the distance, he saw sand. He walked into the shallow water. He poured a bucket of sand over his head.

He saw sand where there was once water. He walked on the sand and into the grasses. He poured a bucket of sand over his head.

**About the Artist**

Subtly and often with humor, Khvay Samnang reflects on various aspects of Cambodian society in order to pose questions of their affects and relevance today. Khvay (b. Svay Rieng, 1982) holds a BA in Fine Arts in Painting from the Royal University of Fine Arts, Phnom Penh (2006). His work has been widely exhibited in Cambodia and international exhibitions include *Arles Photo Festival Night of the Year*, France (2008, 2011), *Forever Until Now*, 10 Chancery Lane Gallery, Hong Kong (2009), *Tokyo 2010*, Tokyo Wonder Site Hongo (2011). He was a resident at Tokyo Wonder Site Aoyama (2010).

# គ្មានចំណងជើង
## ដោយ  ខ្វៃ សំណាង

# Untitled
## Khvay Samnang

15 July - 21 August 2011



Khvay Samnang
*Untitled*, 2011
Digital C-Print